# ផលប៉ះពាល់ដំបូងក្នុងការងារមេភូមិ

មេភូមិទើបតែត្រូវបានជ្រើសតាំងឡើងនៅឆ្នាំនេះនៅទូទាំងព្រះរាជាណាចក្រកម្ពុជា តាមរយៈការជ្រើសរើសរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី១ យោងតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៦ លេខ ០០៤ ស.ណ.ន ស្តីពី *"បែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ"*។ ការជ្រើសរើសនេះតម្រូវឱ្យសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងអាណត្តិទី១ ធ្វើការបោះឆ្នោតជ្រើសរើសមេភូមិនៅគ្រប់ភូមិទាំងអស់ចំនួន១៣.៧០៧ភូមិ។

នៅខណៈពេលនេះ ក្រសួងមហាផ្ទៃកំពុងធ្វើការប្រមូល និងបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសមេភូមិនៅទូទាំងប្រទេស ពោលគឺមិនទាន់មានលទ្ធផលជាផ្លូវការនៅឡើយ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យោងតាមការប៉ាន់ប្រមាណជាបឋមលើលទ្ធផលបោះឆ្នោតជ្រើសរើសមេភូមិបង្ហាញថា ភាគច្រើនលើសលប់នៃមេភូមិទើបជាប់ឆ្នោតថ្មីជាបេក្ខជនចេញមកពីគណបក្សប្រជាជនកម្ពុជា ហើយក៏ផ្លាស់ប្តូរមេភូមិចាស់បានចំនួនច្រើនគួរឱ្យកត់សម្គាល់។

យោងតាមក្រសួងមហាផ្ទៃឱ្យដឹងថា រហូតមកដល់ពេលនេះ មេភូមិអាណត្តិថ្មីនៅទូទាំងប្រទេសត្រូវបានធ្វើការជ្រើសរើសរួចរាល់ចប់សព្វគ្រប់បានប្រមាណ ៨៥% ហើយ ទោះបីជាមានសេចក្តីរាយការណ៍អំពីភាពមិនប្រក្រតីជាបន្តបន្ទាប់ និងការមិនពេញចិត្តរបស់ប្រជាពលរដ្ឋក៏ដូចជាពីសំណាក់មជ្ឈដ្ឋានពាក់ព័ន្ធមួយចំនួនក៏ដោយ។ ការសង្កេតក្រៅផ្លូវការមួយបានប៉ាន់ប្រមាណថា នៅទូទាំងប្រទេស លទ្ធផលនៃការជ្រើសរើសគឺថា គណបក្សប្រជាជនកម្ពុជាទទួលបានតំណែងមេភូមិចំនួនប្រមាណ៩៨% តំណែងអនុប្រធានភូមិចំនួន៩៧% និងសមាជិកភូមិចំនួន៩៩% ធៀបនឹងចំនួនសរុបនៃគណបក្សនយោបាយទាំងបី ដែលមានសំឡេងក្នុងរដ្ឋសភា។ ទន្ទឹមនឹងនេះផងដែរ មេភូមិជាស្ត្រីមានចំនួនតិចតួចបំផុត ពោលគឺមានចំនួនត្រឹមតែ ៣,៤% និងអនុប្រធានភូមិជាស្ត្រីចំនួនប្រមាណ ១៦,៣%។

មានការសង្កេតឃើញនូវបញ្ហាទំនាស់កំពុងកើតឡើង ក្នុងការបោះឆ្នោតជ្រើសរើស និងតែងតាំងមេភូមិជាបន្តបន្ទាប់ និងជាច្រើនករណី ដូចជានៅខេត្តកោះកុង រាជធានីភ្នំពេញ ខេត្តតាកែវ ខេត្តរតនគិរី និងខេត្តបន្ទាយមានជ័យ នៅក្នុងឃុំប៉ោយប៉ែត ហើយបញ្ហានេះបង្ហាញពីភាពទន់ខ្សោយ និងការខ្វះចន្លោះក្នុងការអនុវត្តសេចក្តីណែនាំស្តីពីបែបបទនីតិវិធីនៃការជ្រើសរើស មេភូមិរបស់ក្រសួងមហាផ្ទៃ[១] ក្នុងការដោះស្រាយទំនាស់កើតចេញពីការបោះឆ្នោតជ្រើសរើសនិងតែងតាំងមេភូមិ។ បញ្ហាកើតឡើង ដែលត្រូវបានរាយការណ៍ឱ្យដឹងពីខេត្ត-ក្រុងខាងលើនេះ រួមមានដូចជា អ្នកជាប់ឆ្នោតជាមេភូមិមិនមែនជាអ្នករស់នៅភូមិនោះផ្ទាល់ ចៅសង្កាត់ដើរចេញពីអង្គប្រជុំដោយមិនឱ្យដំណើរការជ្រើសរើសមេភូមិ បញ្ហាមិនគ្រប់កូរ៉ុមក្នុងការប្រជុំបោះឆ្នោតជ្រើសរើសមេភូមិ ការព្យាយាមរកការពិភាក្សាបែងចែកកូតាមេភូមិជាជាងតាមរយៈការបោះឆ្នោត....ជាដើម។

---

[១] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៦ លេខ ០០៤ ស.ណ.ន ស្តីពី *"បែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ"*។

ការងារបោះឆ្នោតដំបូងរបស់មេភូមិជាប់ថ្មីគឺការចែកប័ណ្ណព័ត៌មាន។ សេចក្តីប្រកាសព័ត៌មានរបស់គ.ជ.ប[២] បានឱ្យដឹងថា *"គ.ជ.ប បានផ្តល់ប័ណ្ណទៅឱ្យក្រុមប្រឹក្សា ឃុំ សង្កាត់ ដើម្បី ធ្វើការចែកជូនប្រជាពលរដ្ឋ តាមរយៈមេភូមិ ចាប់ពីថ្ងៃទី ០១ ដល់ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦"*។ ការសង្កេតឃើញថា ក្នុងដំណើរការចែកប័ណ្ណព័ត៌មានបោះឆ្នោតដល់ប្រជាពលរដ្ឋរយៈពេល៣១ថ្ងៃកន្លងទៅ មេភូមិមួយចំនួនប្រតិបត្តិការងារជាដំបូងរបស់ខ្លួនដោយការរើសអើងប្រកាន់គណបក្សនយោបាយ និយាយជារួម បញ្ហាពាក់ព័ន្ធគឺនៅតែជាការបង្ហាញចេញនូវភាពលម្អៀង មិនអព្យាក្រិតរបស់មេភូមិថ្មីដូចគ្នានឹងការប្រតិបត្តិការងាររបស់មេភូមិពីមុនមកដដែលជាដដែល ដោយសារមូលហេតុសំខាន់មួយក្នុងចំណោមមូលហេតុដទៃទៀតនោះគឺ មេភូមិនៅតែជាភ្នាក់ងារសំខាន់របស់គណបក្សនយោបាយកាន់អំណាច។ ការរើសអើងក៏បានរួមចំណែកធ្វើឱ្យមានផលប៉ះពាល់មិនល្អដល់ការចែកប័ណ្ណព័ត៌មាន ដែលអ្នកបោះឆ្នោតចំនួនប្រហែល ១,៧លាននាក់ ពុំទាន់បានទទួលបានព័ត៌មាននៅឡើយ។ បញ្ហាអាចនឹងប៉ះពាល់ដល់សិទ្ធិអ្នកបោះឆ្នោត។

គណៈកម្មាធិការខុមហ្វ្រែលសូមស្វាគមន៍ចំពោះសាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានចេញជូនក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពីការងាររបស់មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិ[៣] ដោយសូមអំពាវនាវដល់ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិទាំងអស់ *"ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលំអៀងក្នុងការអនុវត្តការងាររបស់ខ្លួន ផ្តល់សេវា និងព័ត៌មានដូចគ្នាជូនដល់អ្នកភូមិទាំងអស់ដោយមិនប្រកាន់បក្សពួក និងនិន្នាការនយោបាយ និងបង្កើនកិច្ចសហការជួយដល់អាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់... ។"*

ប៉ុន្តែ សារអំពាវនាវខាងលើនេះក៏មិនគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាប្រឈមឡើយ។ បញ្ហាប្រឈមចំពោះការងារមេភូមិ គឺការពង្រឹងអព្យាក្រិតភាពរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ នៅគ្រប់ដំណាក់កាលនៃបោះឆ្នោត។ ជាក់ស្តែងគឺស្របនឹងអំឡុងពេលនេះ ខណៈដែលគណបក្សកាន់អំណាចក៏មានបំណងរៀបចំពង្រឹងបណ្តាញភូមិ ឃុំ សង្កាត់របស់ខ្លួនផងដែរ។ ម្យ៉ាង មេភូមិគឺជាភ្នាក់ងាររបស់គណបក្សនយោបាយយ៉ាងសកម្ម ក្នុងការងារពង្រឹងគណបក្ស។ មួយវិញទៀត ក៏នៅមានបញ្ហាប្រឈម ជាមន្ទិលផ្នែកគតិយុត្តិនៃអាណត្តិរបស់មេភូមិ ដោយសារតែមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ[៤] ប៉ុន្តែពួកគាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ដូច្នេះ ថាតើក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីអាចធ្វើការដកតំណែង និងឬ ផ្លាស់ប្តូរមេភូមិបានឬទេ?

ឃ ី ្ ី ៤ ០០៦

---

[២] *"សេចក្តីប្រកាសព័ត៌មានរបស់គ.ជ.ប"* ប្រកាសព័ត៌មានលេខ ០៨.០៩២/០៦ គ.ជ.ប/អគ្គ.ពស ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦។

[៣] *សាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជូនក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីពីការងាររបស់មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិ* គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៦។

[៤] សូមមើល ចំណុច៤ នៃសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៦ លេខ ០០៤ ស.ណ.ន -ដ-។